# ព្រះរាជក្រម

នស/រកម/០៧០១/០៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម /០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំពី សម្តេចនាយករដ្ឋមន្ត្រី និងពីរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៦ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖ ៕៚

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ N.T.

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ការប្រើប្រាស់អណ្តូងរ៉ែ ព្រមទាំងរាល់សកម្មភាពទាំងឡាយ ដែលទាក់ទងទៅនឹងប្រតិបត្តិការធនធានរ៉ែនៅព្រះរាជាណាចក្រកម្ពុជា ។ លើកលែងតែប្រតិបត្តិការប្រេងកាតនិងឧស្ម័នត្រូវស្ថិតនៅក្រោមច្បាប់មួយដោយឡែក ។

**មាត្រា ២.-**

ធនធានរ៉ែទាំងអស់ដែលឋិតនៅក្នុងដី លើដី ឬក្រោមដីនៃដែនគោក ភ្នំ ខ្ពង់រាប ដែនទឹក ដែនសមុទ្រ កោះ បាតសមុទ្រ ក្រោមបាតសមុទ្រ ក្នុងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជាជាសម្បត្តិរដ្ឋ ។

**មាត្រា ៣.-**

ធនធានរ៉ែគឺជាសារធាតុទាំងឡាយណា ទោះជាក្នុងទម្រង់រឹង រាវ ឧស្ម័នដែលកកើតឡើងដោយធម្មជាតិតាមដំណើរវិវត្តភូគព្ភសាស្ត្រ ឬជាលទ្ធផលនៃការជីកយកពីក្នុងដី លើដី ក្នុងសមុទ្រ ក្រោមបាតសមុទ្រ មានជាអាទិ៍ត្បូងថ្ម ត្បូងថ្ម រ៉ែអលោហៈ រ៉ែលោហៈ ទឹកខនិជ ថ្ម ក្រួស ខ្សាច់ ដីឥដ្ឋ ប្រេងកាត និងឧស្ម័ន ។

ប្រតិបត្តិការធនធានរ៉ែគឺជាការធ្វើសកម្មភាព បុរេសនា ស្វែងរុករក និងអាជីវកម្មធនធានរ៉ែ ។

បុរេសនាគឺជាការស្វែងរុករកជំហានដំបូងនៅស្រទាប់ដីលើ ដោយប្រើប្រាស់ឧបករណ៍សាមញ្ញ ហើយមានការប៉ះពាល់បន្តិចបន្តួចដល់ផ្ទៃដី ដើម្បីកំណត់វត្តមានធនធានរ៉ែ ដែលមានតម្លៃពាណិជ្ជកម្ម និងអាចជាទិសដៅសម្រាប់ការស្នើសុំអាជ្ញាប័ណ្ណស្វែងរុករក និងអាជីវកម្មធនធានរ៉ែ ។

ការស្វែងរុករកគឺជាការសិក្សាស្រាវជ្រាវក្នុងបំណងរកឱ្យឃើញ ធ្វើតេស្តសន្និស្សន៍រ៉ែ ដើម្បីកំណត់សក្តានុពល ទំហំ គុណភាព បរិមាណ ព្រមទាំងលទ្ធភាពសេដ្ឋកិច្ច អាជីវកម្ម ។ល។

តាមរយៈការធ្វើបុរេសនា ការស្រាវជ្រាវភូគព្ភសាស្ត្រ រូបភូគព្ភសាស្ត្រ **និងគីមីភូគព្ភសាស្ត្រ** ការជីកកកាយ ការខួង ការដឹកជញ្ជូន និងការធ្វើវិភាគដី ដីល្បាប់ ទឹក ថ្ម **និងគំរូរ៉ែផ្សេងៗ**ទៀត ។

អាជីវកម្មធនធានរ៉ែគឺជាប្រតិបត្តិការជីកយកធនធានរ៉ែដែលក្នុងនោះធនធានរ៉ែត្រូវបានយកចេញពីជម្រករ៉ែ ធ្វើប្រព្រឹត្តិកម្ម ដឹកជញ្ជូន លក់ដូរ ឬការនាំចេញក្នុងគោលបំណងពាណិជ្ជកម្ម ។ ដោយឡែកការលក់ដូរ ការនាំចេញ ការនាំចូលលោហធាតុមានតម្លៃ ត្បូងថ្មមានតម្លៃដែលមិនទាន់ច្នៃ និងកែច្នៃរួចហើយ ត្រូវស្ថិតនៅក្រោមបញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជាដែលមានជាធរមាន ។

## ជំពូកទី ២
## អាជ្ញាប័ណ្ណធនធានរ៉ែ

មាត្រា ៤.-

អាជ្ញាប័ណ្ណធនធានរ៉ែគឺជាលិខិតអនុញ្ញាតដែលផ្តល់នូវសិទ្ធិឱ្យទៅសម្បទានិកដោយស្ថាប័នមានសមត្ថកិច្ចដើម្បីអនុវត្តសកម្មភាពប្រតិបត្តិការធនធានរ៉ែ ។

មាត្រា ៥.-

គ្មានរូបវន្តបុគ្គល ឬនីតិបុគ្គលណាអាចធ្វើការស្វែងរុករក ឬធ្វើអាជីវកម្មធនធានរ៉ែ ដោយគ្មានអាជ្ញាប័ណ្ណធនធានរ៉ែ ដែលចេញឱ្យដោយស្ថាប័នមានសមត្ថកិច្ចឡើយលើកលែងតែម្ចាស់កម្មសិទ្ធិ ឬអ្នកកាន់កាប់ស្របច្បាប់លើដីធ្លីដែលជាឯកជនអាចប្រើប្រាស់ ក្រួសខ្សាច់ ថ្ម ដីឥដ្ឋ ដោយមិនចាំបាច់មានអាជ្ញាប័ណ្ណ តែមិនអនុញ្ញាតឱ្យដឹកជញ្ជូនចេញផុតពីព្រំដែនដីធ្លីជាកម្មសិទ្ធិដើម្បីធ្វើអាជីវកម្មនោះទេ ។

ប្រជាពលរដ្ឋខ្មែរអាចធ្វើបុរេសនានៅលើដីរបស់ រដ្ឋឱ្យតែដីនោះរដ្ឋមិនទាន់ចេញអាជ្ញាប័ណ្ណធនធានរ៉ែទៅបុគ្គលដទៃ ។ល។

## មាត្រា ៦.-

រូបវ័ន្តបុគ្គល ឬនីតិបុគ្គល អាចនឹងទទួលអាជ្ញាប័ណ្ណធនធានរ៉ែបានទៅតាមការពិនិត្យពិច័យនៅលើសមត្ថភាពបច្ចេកទេស ហិរញ្ញវត្ថុ និងការចុះបញ្ជីពាណិជ្ជកម្ម

## មាត្រា ៧.-

មុននឹងចូលទៅក្នុងដីដែលជាកម្មសិទ្ធិឯកជនដើម្បីធ្វើការស្វែងរុករកនិងជីកយករ៉ែ សម្បទានិកត្រូវមានការព្រមព្រៀងជាលាយល័ក្ខអក្សរជាមួយម្ចាស់កម្មសិទ្ធិដីធ្លីស្តីពីការមិនជ្រៀតជ្រែក មិនប៉ះពាល់ដល់ទ្រព្យសម្បត្តិនិងការងារព្រមទាំងធ្វើការទូទាត់សងលើការខូចខាតដែលកើតមាននៅលើផ្ទៃដី ដែលបណ្តាលមកពីសកម្មភាពប្រតិបត្តិការធនធានរ៉ែ ។

មុននឹងចូលក្នុងតំបន់ដែលជាកម្មសិទ្ធិរបស់រដ្ឋដែលកំណត់ថាជាតំបន់ការពារ តំបន់បំរុងទុក ឬតំបន់ហាមឃាត់ដើម្បីស្វែងរុករកនិងជីកយករ៉ែ សម្បទានិកត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីស្ថាប័នមានសមត្ថកិច្ច ឬស្ថាប័នអន្តរក្រសួងដែលមានតួនាទីគ្រប់គ្រងលើតំបន់នោះ ។

## មាត្រា ៨.-

ការធ្វើបុរេសនា ការស្វែងរុករក និងធ្វើអាជីវកម្មធនធានរ៉ែនៅលើដីជាកម្មសិទ្ធិរដ្ឋដែលបានកំណត់ជាតំបន់វប្បធម៌ ទីតាំងប្រវត្តិសាស្រ្ត តំបន់បេតិកភ័ណ្ឌជាតិត្រូវហាមឃាត់ ។

## មាត្រា ៩.-

មិនអាចចេញអាជ្ញាប័ណ្ណធនធានរ៉ែឱ្យត្រួតគ្នានៅតំបន់ណាមួយដែលឋិតនៅក្រោមការកាន់កាប់របស់សម្បទានិកមួយផ្សេងទៀតរួចទៅហើយដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីសម្បទានិកមុន ឬការយល់ព្រមជាលាយលក្ខណ៍អក្សរពីរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ដែលបញ្ជាក់ថាសិទ្ធិផ្តាច់មុខរបស់សម្បទានិកមុនពុំមានលក្ខណៈគ្រប់គ្រាន់តាមផ្លូវច្បាប់ឡើយ ។ល។

**មាត្រា ១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែគ្រប់គ្រង ត្រួតពិនិត្យរាល់ប្រតិបត្តិការធនធានរ៉ែ ដើម្បីឱ្យការអនុវត្តន៍បទប្បញ្ញត្តិនិងនីតិវិធីទាំងឡាយនៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែមានប្រសិទ្ធភាព ។

រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែរក្សាទុកសំណុំឯកសារនិងកំណត់ត្រាក្នុងបញ្ជីឯកសារចំពោះរាល់អាជ្ញាប័ណ្ណដែលចេញឱ្យព្រមទាំងឯកសារដែលពាក់ព័ន្ធនឹងអាជ្ញាប័ណ្ណ ។

## ជំពូកទី ៣
## ប្រភេទនៃអាជ្ញាប័ណ្ណធនធានរ៉ែ

**មាត្រា ១១.-**

អាជ្ញាប័ណ្ណធនធានរ៉ែត្រូវបានរៀបចំជាប្រាំមួយប្រភេទ ដើម្បីសម្រួលដល់អ្នកដាក់ពាក្យសុំក្នុងគោលដៅសម្រួលការគ្រប់គ្រងលើការងារស្វែងរុករកនិងធ្វើអាជីវកម្មធនធានរ៉ែ នៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យមានប្រសិទ្ធភាព ។

**១-អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ** អាចផ្តល់ឱ្យចំពោះតែប្រជាពលរដ្ឋខ្មែរប៉ុណ្ណោះ ក្នុងគោលបំណងអនុវត្តការងារស្វែងរុករកនិងធ្វើអាជីវកម្មធនធានរ៉ែដោយប្រើប្រាស់ឧបករណ៍សម្ភារៈសាមញ្ញ ដែលមាននៅក្នុងមូលដ្ឋាន ហើយប្រើប្រាស់កម្លាំងផ្ទាល់ខ្លួនឬជាលក្ខណៈគ្រួសារដែលមានចំនួនមិនលើសពី ៧ (ប្រាំពីរ) នាក់ ។

សិប្បកម្មធនធានរ៉ែអាចធ្វើការស្វែងរុករក និងធ្វើអាជីវកម្មធនធានរ៉ែបានចំពោះតែធនធានរ៉ែដែលរកឃើញក្នុងសភាពជាធនធានរ៉ែរាយប៉ាយនៅក្នុងដីល្បាប់ ខ្សាច់ ក្រួស សិលា ក្នុងផ្ទៃដីកំណត់មួយមានទំហំមិនលើសពី ១ (មួយ) ហិកតា និងជម្រៅមិនហួសពី ៥ (ប្រាំ) ម៉ែត្រ ។

**២-អាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម** អាចផ្តល់ឱ្យរូបវន្តបុគ្គលឬនីតិបុគ្គលដែលមានលក្ខណសម្បត្តិនិងសមត្ថភាពគ្រប់គ្រាន់ ក្នុងបំណងអនុវត្តការងារស្វែងរុករក ធ្វើអាជីវកម្មធនធានរ៉ែសំណង់និងធនធានរ៉ែឧស្សាហកម្មណាមួយបម្រើឱ្យការសាងសង់ ឧស្សាហកម្មគីមី ឧស្សាហកម្មកែច្នៃ ហើយជីកយកពីអណ្តូងរ៉ែបើក ឬការដ្ឋានវាយថ្ម ។ល។

ធនធានរ៉ែសំណង់និងធនធានរ៉ែឧស្សាហកម្មមានជាអាទិ៍ ខ្សាច់ ក្រួស ថ្មសំណង់ ឡាតេរីត ជីផូ្ស ជីផូ្សធ្វើស៊ីម៉ង់ត៍ ថ្មសីលផ្កាថ្ម ហ្វូស្វីត ថ្មកំបោរ ដូឡូមីត ថ្មម៉ាប កៅឡាំង ប៉ាហ្គោឌីត អំបិល ប៉ូតាស ម្នាងសិលា ត្បូងភក់ ត្បូងថ្ម ខ្សាច់ទីតាន ខ្សាច់ស៊ីលីស ឬសមាសធាតុធនធានរ៉ែផ្សេងទៀតដែលប្រើប្រាស់ក្នុងគោលដៅដូចគ្នា ។

**៣-អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ** អាចផ្តល់ឱ្យដល់រូបវ័ន្តបុគ្គល ឬនីតិបុគ្គលដែលមានលក្ខណសម្បត្តិនិងសមត្ថភាពគ្រប់គ្រាន់ក្នុងបំណងស្វែងរុករកនិងធ្វើអាជីវកម្មធនធានរ៉ែ ត្បូងថ្មមានតម្លៃ ពាក់កណ្តាលមានតម្លៃ និងថ្មសំអាង ។

ត្បូងថ្មមានតម្លៃមានជាអាទិ៍ ពេជ្រ ត្បូងទទឹម កណ្តៀង មរកត និងរ៉ែត្បូងថ្មទាំងឡាយដែលមានគុណភាពប្រហាក់ប្រហែល ។

ត្បូងថ្មពាក់កណ្តាលមានតម្លៃមានជាអាទិ៍ សៀកកុន អាមេទីស តូប៉ាស និងរ៉ែត្បូងថ្មទាំងឡាយដែលមានគុណភាពប្រហាក់ប្រហែល ។

ថ្មសំអាងគឺជាថ្មដែលមានកំរិតថ្លាឆ្លុះទាប ឬមិនថ្លាឆ្លុះ ត្រូវបានគេយកទៅប្រើប្រាស់ជាគ្រឿងលំអផ្សេងៗ មានជាអាទិ៍ កាល់សេដូន អាស្វីត អូប៉ាល់ធម្មតា អាហ្គាត ហេវ្រតម៉ាឡាស៊ីក ឈើថ្ម ថ្មថ្លើមអណ្តើក និងថ្មទាំងឡាយដែលមានគុណភាពប្រហាក់ប្រហែល ។

**៤-អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ** អាចផ្តល់ឱ្យចំពោះរូបវ័ន្តបុគ្គលឬនីតិបុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងគោលបំណងកែច្នៃត្បូងថ្មមានតម្លៃ ពាក់កណ្តាលមានតម្លៃ ឬថ្មសំអាង ។

**៥-អាជ្ញាប័ណ្ណស្វែងរុករក** អាចផ្តល់ឱ្យចំពោះរូបវ័ន្តបុគ្គល ឬនីតិបុគ្គលដែលមានលក្ខណសម្បត្តិនិងសមត្ថភាពគ្រប់គ្រាន់ដើម្បីធ្វើការស្វែងរុករកនិងសិក្សាអំពីសក្តានុពលធនធានរ៉ែ ។

**៦-អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ** ត្រូវបានផ្តល់ឱ្យចំពោះតែសម្បទានិកដែលមានអាជ្ញាប័ណ្ណស្វែងរុករកប៉ុណ្ណោះ ក្នុងគោលបំណងស្វែងរុករកនិងជីកយករ៉ែណាដែលមានជម្រករ៉ែមានប្រសិទ្ធភាពសេដ្ឋកិច្ច ហើយឋិតនៅតែក្នុងវង្វង់ព្រំដែននៃអាជ្ញាប័ណ្ណស្វែងរុករក ។ល។

សម្បទានិកស្វែងរុករកត្រូវតែដាក់ឱ្យពិនិត្យនូវការវិភាគបច្ចេកទេសហិរញ្ញវត្ថុ បរិស្ថាន សេដ្ឋកិច្ច និងសង្គម ក្នុងគោលបំណងកំណត់លទ្ធភាពសេដ្ឋកិច្ចសង្គមនៃទម្រង់ប្រតិបត្តិការជីកយករ៉ែ ដើម្បីសុំការយល់ព្រមពីរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ។

បែបបទនិងមាតិកានៃរបាយការណ៍ ការសិក្សាសមិទ្ធិលទ្ធភាពចុងក្រោយនិងឯកសារយោងព្រមទាំងល័ក្ខខ័ណ្ឌទាំងឡាយនៃការចេញអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែនឹងមានចែងក្នុងអនុក្រឹត្យ ។

**មាត្រា ១២.-**

ក្នុងករណីដែលរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែកំណត់ថា ពាក្យសុំអាជ្ញាប័ណ្ណស្វែងរុករក ឬអាជីវកម្មធនធានរ៉ែជាគម្រោងមានទ្រង់ទ្រាយធំនិងមានផលប្រយោជន៍ពិសេសដល់ប្រទេសជាតិ រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែត្រូវធ្វើការចរចាជាមួយអ្នកស្នើសុំដើម្បីឈានទៅដល់កិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែ ដែលត្រូវបន្ថែមទៅលើអាជ្ញាប័ណ្ណធនធានរ៉ែ ។

**មាត្រា ១៣.-**

ចំពោះតំបន់ដែលដឹងពីសក្តានុពលធនធានរ៉ែ ហើយដែលមិនទាន់ចេញអាជ្ញាប័ណ្ណ រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែអាចកំណត់តាមការប្រកាសជាសាធារណៈថាជាតំបន់រក្សាទុកសំរាប់ធ្វើការដេញថ្លៃ ដោយរៀបចំឱ្យមានការវាយតម្លៃការចរចាជាផ្លូវការ ដើម្បីចេញអាជ្ញាប័ណ្ណធនធានរ៉ែសមស្របមួយ ឬតម្រូវឱ្យមានការចរចាធ្វើកិច្ចព្រមព្រៀងធនធានរ៉ែបន្ថែមដូចមានចែងក្នុងមាត្រា ១២ ។

## ជំពូកទី ៤
## នីតិវិធីនៃការចេញអាជ្ញាប័ណ្ណធនធានរ៉ែ

**មាត្រា ១៤.-**

ប្រជាពលរដ្ឋខ្មែរអាចដាក់ពាក្យសុំអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែដោយខ្លួនឯងផ្ទាល់តាមមន្ទីរជំនាញរបស់ក្រសួងទទួលបន្ទុកវិស័យរ៉ែនៅតាមបណ្តាខេត្ត ក្រុង ដែលតំបន់អាជ្ញាប័ណ្ណនោះស្ថិតនៅ ។ល។

មាត្រា ១៥.-

រូបវ័ន្តបុគ្គល ឬនីតិបុគ្គល ត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណធនធានរ៉ែទាំងឡាយផ្សេងទៀតក្រោមអំណាចនៃច្បាប់នេះទៅរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ។

មាត្រា ១៦.-

រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរពីការយល់ព្រម ឬការបដិសេធនៃលើការស្នើសុំអាជ្ញាប័ណ្ណធនធានរ៉ែ ក្នុងរយៈពេលយ៉ាងយូរ ៤៥ (សែសិបប្រាំ) ថ្ងៃ ក្រោយពីថ្ងៃបានទទួលសំណុំលិខិតស្នើសុំគ្រប់គ្រាន់តាមបែបបទបច្ចេកទេស ។

មាត្រា ១៧.-

លើកលែងតែអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ សម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែផ្សេងទៀត ក្រោមអំណាចនៃច្បាប់នេះអាចសុំបន្ត កែប្រែ ប្រគល់ជូនវិញ ដាក់បញ្ចាំ ផ្ទេរសិទ្ធិ ឬបន្តជាមរតកបានដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ។

មាត្រា ១៨.-

អាជ្ញាប័ណ្ណធនធានរ៉ែក្រោមអំណាចនៃច្បាប់នេះ អាចព្យួរ ឬលុបចោលចំពោះសម្បទានិកណាដែលបំពានច្បាប់នេះ ។

នីតិវិធីនៃការព្យួរទុក ការដកហូតអាជ្ញាប័ណ្ណ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១៩.-

សម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែ ក្រោមអំណាចនៃច្បាប់នេះត្រូវដាក់ជូនរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែពិនិត្យនូវលិខិតស្នើសុំរបាយការណ៍ ផែនការនិងលិខិតជូនដំណឹងតាមវេលាកំណត់ហើយត្រូវរក្សាទុកសៀវភៅកំណត់ត្រានិងឯកសារ ។ល។

មាត្រា ២០.-

ការរក្សាការសំងាត់លើឯកសារ ព័ត៌មានទាំងឡាយដូចមានចែងក្នុងមាត្រា ១៩ នៃច្បាប់នេះ ត្រូវធ្វើរហូតដល់ចុងបញ្ចប់នៃអាជ្ញាប័ណ្ណធនធានរ៉ែ ឬរហូតដល់មានការអនុញ្ញាតពីសម្បទានិកឱ្យធ្វើការផ្សព្វផ្សាយជាចំហលើកលែងតែ :

- ព័ត៌មានដែលទាក់ទងនឹងបរិស្ថាននិងសង្គមអាចផ្សព្វផ្សាយជាសាធារណៈបានដោយគ្រាន់តែរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែជូនដំណឹងដល់សម្បទានិកនោះប៉ុណ្ណោះ

-ក្រសួងទទួលបន្ទុកវិស័យរ៉ែចងក្រងបោះពុម្ពផ្សាយនូវស្ថិតិដែលស្រង់ចេញពីឯកសារនិងព័ត៌មានទាំងឡាយរបស់សម្បទានិកឱ្យតែមានការទាក់ទងទៅនឹងការវិភាគផ្នែកធនធានរ៉ែរបស់ជាតិ ។

## ជំពូកទី ៥
## ប្រតិបត្តិការស្វែងរុករកនិងអាជីវកម្មធនធានរ៉ែ

មាត្រា ២១.-

សម្បទានិកឬអ្នកចុះកិច្ចសន្យាបន្តនីមួយៗ ត្រូវទទួលខុសត្រូវលើការដឹកនាំប្រតិបត្តិការ ស្វែងរុករកនិងធ្វើអាជីវកម្មធនធានរ៉ែ នឹងត្រូវអនុវត្តទៅតាមការកំណត់ដូចខាងក្រោមនេះ :

១-ដំណើការប្រតិបត្តិការឱ្យបានត្រឹមត្រូវនិងមានប្រសិទ្ធភាពតាមលក្ខណៈបច្ចេកទេសនិងហិរញ្ញវត្ថុ ដែលនឹងលំអិតក្នុងកម្មវិធីការងារស្វែងរុករក ឬការសិក្សាអំពីសមិទ្ធិលទ្ធភាពអណ្តូងរ៉ែ

២-ការពារបរិស្ថានដូចមានលំអិតក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងគ្រប់គ្រងធនធានធម្មជាតិ ការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ផែនការគ្រប់គ្រងបរិស្ថាន ផែនការលុបអណ្តូងរ៉ែ និងការធានាផ្នែកហិរញ្ញវត្ថុ

៣-ធានាការការពារសុខភាពនិងសុវត្ថិភាពពលករដែលនឹងលំអិតក្នុងកម្មវិធីផែនការអណ្តូងរ៉ែ កម្មវិធីសុខភាព និងសុវត្ថិភាពក្នុងអណ្តូងរ៉ែ រាប់បញ្ចូលទាំងការការពារគ្រោះថ្នាក់ បែបបទរាយការណ៍ស្តីពីគ្រោះថ្នាក់នេះ ល.ល.

៤-ការពារសុវត្ថិភាពដល់សាធារណជននៅក្នុងនិងជុំវិញតំបន់អណ្តូងរ៉ែដែលនឹងលំអិតក្នុងផែនការអណ្តូងរ៉ែ

៥-ធ្វើការអប់រំ បណ្តុះបណ្តាលនិងផ្តល់ការងារដល់ប្រជាពលរដ្ឋខ្មែរដែលនឹងលំអិតក្នុងកម្មវិធីផ្តល់ការងារអប់រំ បណ្តុះបណ្តាល

៦-ប្រើប្រាស់ឱ្យអស់លទ្ធភាពនូវទំនិញនិងសេវាកម្មក្នុងព្រះរាជាណាចក្រកម្ពុជានៅតាមទីកន្លែង និងពេលវេលាសមស្រប ។

រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ អាចកំណត់ភាពចាំបាច់បន្ថែមសម្រាប់ការងារខាងលើដោយយោងទៅតាមប្រភេទអាជ្ញាប័ណ្ណធនធានរ៉ែ និងទំហំប្រតិបត្តិការនោះ ។

មាត្រា ២២.-

ការណែនាំលើបែបបទ ការបញ្ចើន ការពង្រីកផែនការនិងមាតិកានៃរាល់សំណុំលិខិតចាំបាច់និងកម្មវិធីការងារ ការធានាផ្នែកហិរញ្ញវត្ថុសម្រាប់អនុវត្តឱ្យបានត្រឹមត្រូវនោះនឹងមានចែងនៅក្នុងប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ។

មាត្រា ២៣.-

ក្នុងករណីចាំបាច់នីមួយៗ រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែត្រូវចាត់តាំងមន្ត្រីមានសមត្ថកិច្ចដើម្បីពិនិត្យការអនុវត្តន៍ច្បាប់នេះ។

មន្ត្រីដែលត្រូវបានចាត់តាំងត្រូវ :

១-ទទួលខុសត្រូវចំពោះរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែលើរបៀបរបបគ្រប់គ្រងស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ

២-រៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីសកម្មភាពជាប្រចាំលើការងារស្វែងរុករក និងជីកយករ៉ែតាមឆ្នាំបន្តបន្ទាប់ ហើយដាក់របាយការណ៍នោះជូនរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ

៣-ប្រមូលផ្តុំព័ត៌មាននិងរក្សាទុកឯកសារប្រតិបត្តិការស្វែងរុករក ជីកយករ៉ែ ការដឹកជញ្ជូន ប្រព្រឹត្តិកម្ម ការរកទីផ្សារ និងការនាំចេញធនធាននិងផលិតផលរ៉ែ ។ល។

៤-ធ្វើការតាមដាននិងពិនិត្យ ដើម្បីបញ្ជាក់ពីការអនុវត្តន៍បទប្បញ្ញត្តិទាំងអស់នៃច្បាប់នេះ

៥-ត្រួតពិនិត្យការអនុវត្តន៍បទបញ្ជាឱ្យបានត្រឹមត្រូវលើសុខភាព និងសុវត្ថិភាពរបស់ពលករ និងសាធារណជនទូទៅ និងការពារបរិស្ថាន

៦-ទទួលតួនាទីផ្សេងៗទៀតតាមការកំណត់របស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ។

អំណាចនិងតួនាទីរបស់មន្ត្រីដែលត្រូវបានចាត់តាំងដើម្បីត្រួតពិនិត្យធ្វើអធិការកិច្ច និងរាយការណ៍ពីសកម្មភាពការងារស្វែងរុករក ជីកយករ៉ែ ស្រាវជ្រាវ ការវិភាគពាក់ព័ន្ធនឹងរបៀបរបបគ្រប់គ្រងក្រោមអំណាចនៃច្បាប់នេះនឹងមានចែងនៅក្នុងអនុក្រឹត្យ ។

**មាត្រា ២៤.-**

តាមការសម្របសម្រួលរបស់ក្រសួងទទួលបន្ទុកវិស័យរ៉ែ សម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែត្រូវសុំយោបល់ពីក្រសួងពាក់ព័ន្ធ ដើម្បីអនុវត្តប្រតិបត្តិការស្វែងរុករកនិងធ្វើអាជីវកម្មធនធានរ៉ែនៅក្នុងមូលដ្ឋាន ខេត្ត ក្រុង ស្រុក ខណ្ឌ តាមគោលការណ៍អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៦
## សម្បទានិកនិងម្ចាស់កម្មសិទ្ធិដី

**មាត្រា ២៥.-**

សម្បទានិកដែលមានអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវសងទៅម្ចាស់កម្មសិទ្ធិដីទាំងក្នុងនិងក្រៅតំបន់អាជ្ញាប័ណ្ណធនធានរ៉ែ ចំពោះការខូចខាតទាំងឡាយដែលបណ្តាលមកពីប្រតិបត្តិការអាជីវកម្មធនធានរ៉ែរបស់ខ្លួនដោយមិនគិតថាការខូចខាតនោះជាឧបទ្ទវហេតុ ឬជាការដឹងមុន ។

-ក្នុងករណីការខូចខាតណាដែលបណ្តាលមកពីប្រតិបត្តិការអាជីវកម្មធនធានរ៉ែរបស់សម្បទានិកចាប់ពីពីរឡើងទៅ សម្បទានិកទាំងនោះត្រូវរួមគ្នាសងទៅតាមការខូចខាត ។

សំណងទាំងនោះត្រូវអនុវត្តដូចខាងក្រោមនេះ :

-ប្រសិនបើជាតំបន់ប្រតិបត្តិការធនធានរ៉ែដែលមានកំណត់នៅក្នុងអាជ្ញាប័ណ្ណធនធានរ៉ែប៉ះពាល់ទៅលើដីកម្មសិទ្ធិ ម្ចាស់ដីត្រូវអនុញ្ញាតឱ្យសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែធ្វើប្រតិបត្តិការធនធានរ៉ែនៅលើដីនោះ ដោយមានការព្រមព្រៀងគ្នាទៅវិញទៅមកជាមុន ដែលក្នុងនោះម្ចាស់ដីត្រូវបានទទួលសំណងសមរម្យនិងយុត្តិធម៌

-សំណងនោះត្រូវសងតាមពេលវេលា ឬសងផ្តាច់តែម្តងតាមការព្រមព្រៀងរវាងម្ចាស់ដី និងសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែ

- ក្នុងករណីម្ចាស់ដីនិងសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែមិនអាចស្រុះស្រួលគ្នាលើសំណងបានទេនោះ រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែត្រូវសម្រួលដោះស្រាយ បើមិនបានសំរេចទេ ត្រូវធ្វើសំណើទៅរាជរដ្ឋាភិបាលដើម្បីបង្កើតគណៈកម្មការចំរុះមួយសំរាប់ដោះស្រាយករណីនេះ

- ក្នុងករណីដែលភាគីទាំងអស់មិនយល់ព្រមតាមដំណោះស្រាយរបស់គណៈកម្មការចំរុះទេនោះ សេចក្តីសំរេចជាសមត្ថកិច្ចរបស់តុលាការ ។

មាត្រា ២៦.-

ក្នុងករណីដែលផ្ទៃដីទាំងមូល ឬចំណែកណាមួយនៃតំបន់ប្រតិបត្តិការធនធានរ៉ែ ដែលមានកំណត់នៅក្នុងអាជ្ញាប័ណ្ណធនធានរ៉ែ មិនទាន់បានផ្តល់កម្មសិទ្ធិជូនទៅបុគ្គលណាម្នាក់ទេនោះ អាជ្ញាធរមានសមត្ថកិច្ចមិនអាចចេញកម្មសិទ្ធិផ្ទៃដីទាំងមូល ឬចំណែកណាមួយនៃតំបន់ប្រតិបត្តិការធនធានរ៉ែដែលមានកំណត់នៅក្នុងអាជ្ញាប័ណ្ណធនធានរ៉ែទៅឱ្យបុគ្គលណាម្នាក់បានឡើយ លើកលែងតែមានការអនុញ្ញាតពីរាជរដ្ឋាភិបាលតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ។

ប្រសិនបើតំបន់ប្រតិបត្តិការអាជ្ញាប័ណ្ណធនធានរ៉ែនោះមានប្រជាពលរដ្ឋកំពុងរស់នៅមុនកាលបរិច្ឆេទនៃការចេញអាជ្ញាប័ណ្ណ សម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវអនុវត្តសំណងដូចមានចែងក្នុងមាត្រា ២៥ ដែរ ។ល។

# ជំពូកទី ៧
## បទប្បញ្ញត្តិហិរញ្ញវត្ថុ

**មាត្រា ២៧.-**

អ្នកដាក់ពាក្យសុំ ឬសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែត្រូវបង់ជូនរដ្ឋនូវថ្លៃចុះបញ្ជី ពាក្យសុំការពន្យារ បន្ត ការផ្ទេរផ្សេងៗនិងឈ្នួលដីប្រចាំឆ្នាំ ។

**មាត្រា ២៨.-**

សម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែទាំងអស់ លើកលែងតែសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណស្វែងរុករក និងសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ត្រូវបង់ជូនរដ្ឋនូវសួយសារលើតម្លៃធនធានរ៉ែដែលទាញយកបាន ។

សម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើត្រូវរក្សាទុកនូវបញ្ជីគណនេយ្យ ហើយត្រូវផ្តល់ជូនរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែនូវរបាយការណ៍ ឬបញ្ជីដែលទាក់ទងនឹងពត៌មាននេះ ។

**មាត្រា ២៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែអាចធ្វើសេចក្តីប្រកាសដល់សម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែ ដើម្បីផ្តល់ពត៌មានបន្ថែមពីកិច្ចសន្យាលក់ អង្កេតនិងតាមដានត្រួតពិនិត្យរាល់បញ្ជីគណនេយ្យ និងពិគ្រោះជាមួយសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែដើម្បីកំណត់ថ្លៃផលិតផលរ៉ែ ។

**មាត្រា ៣០.-**

ត្រូវហាមដាច់ខាតក្នុងការដឹកជញ្ជូនធនធានរ៉ែចេញ ក្នុងករណីដែលធនធានរ៉ែនោះមិនទាន់បានបង់សួយសារ ឬគ្មានលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សរពីរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ ៕ល៕

**មាត្រា ៣១.-**

យោងតាមច្បាប់ដែលមានជាធរមាន របបពន្ធអាករពិសេសមួយនឹងត្រូវបានបង្កើតឡើងសម្រាប់អនុវត្តលើផលិតផលនិងប្រាក់ចំណូលពីប្រភេទអាជ្ញាប័ណ្ណធនធានរ៉ែទាំង ៦ (ប្រាំមួយ) ដូចមានចែងក្នុងមាត្រា ១១ ។

**មាត្រា ៣២.-**

អត្រាសួយសារលើតម្លៃធនធានរ៉ែ នីតិវិធីនៃការបង់សួយសារជូនរដ្ឋនិងការលើកទឹកចិត្តដល់មន្ត្រីមានសមត្ថកិច្ចដែលចែងក្នុងមាត្រា ២៣ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង ។

ពន្ធអាករ ពន្ធគយ ពន្ធលើចំណែកភាគហ៊ុន ពន្ធប្រាក់ចំណែកផ្ទាល់ខ្លួន សិទ្ធិធានធន បែបបទចំណាយ របៀបបង់ពន្ធ គោលការណ៍ និងការអនុវត្តន៍គណនេយ្យនិងហិរញ្ញកិច្ច ការកំណត់ការខាតបង់ការលើកលែងពន្ធ និងការលើកទឹកចិត្តដល់ការវិនិយោគទុនលើវិស័យរ៉ែ ត្រូវអនុវត្តតាមច្បាប់ដែលមានជាធរមាន ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**មាត្រា ៣៣.-**

បុគ្គលណាដែលធ្វើប្រតិបត្តិការស្វែងរុករកធនធានរ៉ែ ដោយគ្មានអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវពិន័យជាប្រាក់ចំនួនពី ៥០០.០០០ (ហាសិបម៉ឺន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

ក្នុងករណីមិនរាងចាលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ឬផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ)ឆ្នាំ ឬត្រូវផ្តន្ទាទោសទាំងពីរ ។ល។

មាត្រា ៣៤.-

បុគ្គលណាដែលធ្វើប្រតិបត្តិការស្វែងរុករក ល្មើសនឹងមាត្រា ៧ វាក្យខ័ណ្ឌទី ២ ឬមាត្រា ៨ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ខែ ទៅ ២ (ពីរ)ឆ្នាំ ឬត្រូវផ្តន្ទាទោសទាំងពីរ ។

មាត្រា ៣៥.-

បុគ្គលណាដែលធ្វើប្រតិបត្តិការជីកយករ៉ែ ដោយគ្មានអាជ្ញាប័ណ្ណធនធានរ៉ែ ឬល្មើសនឹងមាត្រា ៧ ឬមាត្រា ៨ នៃច្បាប់នេះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនស្មើនឹង ៣ (បី) ដងនៃតម្លៃចាន់ស្មាន តាមរយៈពេលដែលផលរ៉ែត្រូវបានជីកយកដោយផ្អែកលើទំហំឧបករណ៍ គ្រឿងចក្រផលិតកម្មប្រើប្រាស់និងបរិមាណរ៉ែដែលមានក្នុងទីតាំងនោះ ហើយនិងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន)រៀលក្នុងមួយថ្ងៃ ដោយគិតចាប់ពីថ្ងៃដែលបុគ្គលនោះប្រព្រឹត្តខុសរហូតដល់ថ្ងៃដែលសកម្មភាពប្រតិបត្តិការជីកយករ៉ែនោះត្រូវបានបញ្ឈប់ និងផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ដោយមិនទាន់គិតដល់សំណងនៃការខូចខាតផ្សេងទៀត ។ រីឯឧបករណ៍គ្រឿងចក្រផលិតកម្មផ្សេងៗទៀតត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

មាត្រា ៣៦.-

បុគ្គលណាដែលធ្វើប្រតិបត្តិការជីកយករ៉ែដោយអាជ្ញាប័ណ្ណធនធានរ៉ែអស់សុពលភាព ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ៣៥ នៃច្បាប់នេះ ។

មាត្រា ៣៧.-

សម្បទានិកណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣០ នៃច្បាប់នេះ ត្រូវពិន័យជាប្រាក់ដែលមានចំនួនទ្វេជាពីរនៃតម្លៃធនធានរ៉ែដែលបានជីកចេញ ឬត្រូវដកហូតអាជ្ញាប័ណ្ណធនធានរ៉ែ ឬត្រូវទទួលទោសទាំងពីរ ។៚.

មាត្រា ៣៨.-

សម្បទានិកដែលមិនអនុញ្ញាតឱ្យមន្ត្រីដែលមានសមត្ថកិច្ចចុះត្រួតពិនិត្យដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ចូលធ្វើការត្រួតពិនិត្យនៅក្នុងការដ្ឋានប្រតិបត្តិការធនធានរ៉ែរបស់ខ្លួននឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន)រៀល ឬត្រូវព្យួរទុកអាជ្ញាប័ណ្ណធនធានរ៉ែ រយៈពេលមិនលើសពី ៦ (ប្រាំមួយ) ខែ ។

ក្នុងករណីមិនរាងចាល ត្រូវដកហូតអាជ្ញាប័ណ្ណធនធានរ៉ែជាស្ថាពរ ។

មាត្រា ៣៩.-

បុគ្គលណាដែលមិនមែនជាម្ចាស់កម្មសិទ្ធិដីស្របច្បាប់ ហើយធ្វើឱ្យរាំងស្ទះដល់ប្រតិបត្តិការធនធានរ៉ែរបស់សម្បទានិកដែលមានអាជ្ញាប័ណ្ណធនធានរ៉ែត្រឹមត្រូវតាមច្បាប់នោះ នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ដល់ ១(មួយ)ខែ ។

មាត្រា ៤០.-

មន្ត្រីមានសមត្ថកិច្ចនៃក្រសួងទទួលបន្ទុកវិស័យរ៉ែដែលបានឃុបឃិត ឬប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ត្រូវទទួលទោសរដ្ឋបាល ដោយពុំទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងៗទៀត ។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

មាត្រា ៤១.-

រូបវ័ន្តបុគ្គល ឬនីតិបុគ្គលណាដែលបានចាប់ផ្តើមស្វែងរុករកឬធ្វើអាជីវកម្មធនធានរ៉ែ ហើយមានលិខិតអនុញ្ញាតជាផ្លូវការមុនពេលច្បាប់នេះចូលជាធរមាន អាចបន្តសកម្មភាពការងារបាន ប៉ុន្តែតម្រូវឱ្យដាក់ពាក្យបំពេញបែបបទសុំអាជ្ញាប័ណ្ណធនធានរ៉ែថ្មី ទៅតាមបញ្ញត្តិនៃច្បាប់នេះយ៉ាងយូរ ៩០ (កៅសិប) ថ្ងៃ ។ល។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ៤២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។ល។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

**ហត្ថលេខា**

**ស៊ុយ សែម**

លេខ: ១៤១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**